# ប្រមាត់ប្រមង់សម័យតេជោ

ខ្ញុំជឿថាបានកើតទាន់សម័យប្រមាត់ប្រមង់ពីរជំនាន់។ បើមិនច្រឡំទេ ជំនាន់ទីមួយគឺម្ដុំ ឆ្នាំ១៩៤៨ឬ១៩៤៩(មិនច្បាស់) នឹងជំនាន់ទីពីរគឺនៅឆ្នាំ១៩៥៤។
នាទីនេះមិនហ៊ានប៉ះពាល់ដល់ប្រមាត់ប្រមង់ដែលបណ្ឌិតកេង វ៉ាន់សាក់ បានរៀបរាប់ហូរហែរមកហើយនោះទេ។

ប្រមាត់ប្រមង់ក្នុងនាទីនេះមានបំណងត្រឹមតែបង្ហាញនូវវិធីដែលគេ(យួន)ចាប់កូនខ្មែរវ័យក្មេងយកទៅ លាងខួរក្បាល បញ្ចូលមនោគមវិជ្ជា
ធ្វើឲ្យពួកគេវង្វេងកំណើតរបស់ខ្លួនហើយបែរជាបំរើគេដោយស្មោះត្រង់ ទោះជាទង្វើរបស់ខ្លួននោះធ្វើឲ្យស្លាប់ជាតិដើមរបស់ខ្លួនក៏ដោយ។
គួរកត់សំគាល់ថាក្នុងចំណោមកុមារខ្មែរដែលប្រមាត់ប្រមង់ចាប់យកទៅកាលណោះ មានលោកប៉ែន សុវណ្ណ នឹង លោកចាន់ ស៊ី ដែលមាននាទីជាអតីតនាយករដ្ឋមន្ត្រី
នៃសាធារណរដ្ឋប្រជាមានិតុកម្ពុជាផងដែរ។ នេះជារឿងចាស់ ជារឿងកន្លងហួសទៅហើយ បើនឹងបំភ្លេចក៏ប្រឹងបំភ្លេចមិនបានដែរ។
តទៅនេះជារឿងថ្មី តែក៏មិនថ្មីស្រឡាងដែរ។

សម័យតេជោ ប្រមាត់ប្រមង់មិនចាំបាច់ចាប់ក្មេងខ្មែរយកទៅលាងខួរឯក្រុងហាណូយដូចកាលដើមទៀតទេ។ គេ(យួន)ហាក់មានការអនុញ្ញាតិឲ្យចូលមករស់នៅក្នុងស្រុកខ្មែរ
ស្រេចតែអំពើចិត្តឥតមាននរណា ឬអង្គការណាទប់ទល់បានឡើយ។ គេមានសេរីភាពចូលមកលាងខួរកូនខ្មែរនៅក្នុងដែនដីខ្មែរតែម្ដង។ មើលចុះ អត្ថបទលោកយាង សុជា មេត្តា
វិទ្យុអាស៊ីសេរី ចុះថ្ងៃ១២ធ្នូ ២០១៣ ផ្សាយតាមរយៈ ខេអាយម៉េឌា បានឲ្យដឹងថា នៅឯព្រែកខ្សាយខ ស្រុកពាមរ៍ ខេត្តព្រៃវែង សាលារៀនមួយដែលមាន៧ថ្នាក់ បានបើក
ឲ្យសិស្សចូលរៀនកាលពីថ្ងៃ១១ ធ្នូ ២០១៣នេះ។ មិនមែនជាស្នាដៃរបស់លោកហ៊ុន សែនទេ។ សាលានេះសង់អស់ប្រាក់ចំនួន១៩ម៉ឺនដុល្លាអាមេរិក ក្នុងនោះ១៥ម៉ឺនដុល្លា
បានមកពីគណកម្មការប្រជាជន ខេត្តដុងថាប ប្រទេសវៀតណាម រីឯ៤ម៉ឺនដុល្លាទៀត គេពុំបានបញ្ជាក់ថាបានមកពីណាទេ។ សាលាបឋមសិក្សានោះគេដាក់ឈ្មោះថាសាលា
សាមគ្គីកម្ពុជា–វៀតណាម ក្រោមកិច្ចឧបត្ថមរបស់សមាគមសហព័ន្ធ ខ្មែរ–វៀតណាម ដែលមានឈ្មោះចាវ វ៉ាងជី ជាប្រធាន។ យួនចិត្តល្អណាស់ គេអែអង្គាសប្រាក់គ្នាគេ
មកសង់សាលាក្នុងទឹកដីខ្មែរ ធ្វើម្ដេចមិនឲ្យខ្មែរដឹងគុណគេកើតទៅ?។ គេក៏មិនភ្លេចបញ្ជាក់ដែរថា ក្នុងចំណោមថ្នាក់រៀនទាំង៧នោះ មាន៥ថ្នាក់បង្រៀនជាភាសាយួនសំរាប់កូនយួន
រីឯ២ថ្នាក់ទៀតសំរាប់កូនខ្មែរ បង្រៀនជាភាសាខ្មែរ អាចបញ្ចូលភាសាយួនខ្លះបានបើចង់។ គេឲ្យដឹងទៀតថាសាលា បែបនេះបានត្រូវកសាងនៅភ្នំពេញរួចហើយៗនឹងត្រូវកសាង
ថែមនៅទីផ្សេងទៀតបើមានលទ្ធភាព។ តើកូនខ្មែរអាចចាប់អារម្មអ្វីខ្លះអំពីរឿងសាលារៀនតូចមួយនេះ?

– យោងតាមដំណើរសាលានៅឯព្រែកខ្សាយខ ស្រុកពាមរ៍ ខេត្តព្រៃវែង ខាងលើដែលមាន ៥ថ្នាក់សំរាប់កូនយួនទល់នឹង២ថ្នាក់សំរាប់កូនខ្មែរ តើគេអាចសន្និដ្ឋានបានទេថា
នៅទីនោះមានយួនដល់ទៅ៧១% ឯខ្មែរវិញមានតែ២៩%? តើលោកជៀម យាប សមាជិកសភា តំណាងបក្សប្រជាជនខេត្តព្រៃវែងមានបើជ្រាបរឿងនេះដែរឬទេ?។
តើវាមានតែរឿងអីចឹងមែនទេតាមបណ្ដោយព្រំដែនខ្មែរ–យួន គិតតាំងពីមាត់សមុទ្រទៅដល់កន្ទុយនាគ?។

– រឿងមួយដែលធ្វើឲ្យខ្ញុំព្រឺក្បាលនោះគឺឈ្មោះសាលាដែលគេដាក់ថា *សាលាសាមគ្គីកម្ពុជា–វៀតណាម*។ មានន័យអ្វីដែរដែលគេទាត់ពាក្យមិត្តភាពចោលហើយយកពាក្យសាមគ្គី
មកជំនួសវិញនោះ។

– រឿងដែលគួរឲ្យព្រឺក្បាលជាងនេះទៅទៀតគឺសាលាបឋមសិក្សានេះ រួមទាំងសាលានៅភ្នំពេញផងត្រូវបានគ្រប់គ្រងដោយ*សមាគមសហព័ន្ធខ្មែរ–វៀតណាម*។ អ្វីទៅដែលគេហៅថា
សហព័ន្ធខ្មែរ–វៀតណាមនោះ?។ តើនៅប៉ុន្មានជំហានទៀតយើងនឹងដើរទៅដល់*សហព័ន្ធឥណ្ឌូចិន*ដែលមានយួនត្រួតត្រានោះ?

– យួនូបនីយកម្មស្រុកខ្មែរមានភាពសាហាវ លឿនលឿនលើសពីជំនាន់ណាៗទាំងអស់។

– គេថាខ្មែរយើងបានធ្វើដំណើរមកដល់មាត់ជ្រោះមរណៈហើយ ខ្ញុំយល់ថាខ្មែរយើងបានធ្លាក់ក្នុងជ្រោះមរណៈរួចទៅហើយ គ្រាន់តែមិនទាន់ដល់បាតងើបលែងរួចតែប៉ុននោះ តែក៏
មិនជាឆ្ងាយប៉ុន្មានដែរ។

– នរណាក៏ដឹងដែរថាយួនចង់ធ្វើអ្វីក៏បានទាំងអស់នៅក្នុងស្រុកខ្មែរ សូមបីតែសំផឹងយួនក៏លោកហ៊ុន សែនមិនហ៊ានប៉ះពាល់ដែរ។ ប្រមាត់ប្រមង់សម័យតេជោ គេចូលមកលាងខួ
ខ្មែរ ដល់ក្នុងផ្ទះ ធ្វើយួនូបនីយកម្មដោយសេរីឥតមាននរណាទប់ទល់ឡើយ។ តើខ្មែរអាចនឹងរស់ក្នុងនាមជាប្រជាជាតិមួយនឹងគេក្នុងលោកបានឬទេ?
សូមស្ដេះរឿងសាលារៀនតូចមួយនេះត្រឹមប៉ុននេះចុះ កុំឲ្យគេចោទថារើសអើងជាតិសាសន៍។
អ៊ុំ ហាក់
១៦ធ្នូ ២០១៣